ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:២៧១/២១-៣-២០១២

សាលដីកា

លេខ:១៨ក្រVI(ផ)/២១-០៦-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី២១-៦-២០១៣ ដែលមានសមាសភាពដូចតទៅ:

**<u>សមាសភាពក្រុមប្រឹក្សា</u>**

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធានក្រុមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

**<u>តំណាងមហាអយ្យការ</u>**

| | | |
|---|---|---|
| លោក | [redacted] | ជាព្រះរាជអាជ្ញា |

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៧១ចុះថ្ងៃទី ២១-៣-២០១២៖

-ជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កន្លែងកំណើតនៅភូមិក្បាលបឹងសេះ ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម និងទីលំនៅសព្វថ្ងៃ[redacted] ស្រុកតំបែរ ខេត្តកំពង់ចាម មុខរបរកសិករ ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ [redacted](វ) ប្រពន្ធឈ្មោះ [redacted]មានកូន០១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៨-៨-២០១១ ឃុំខ្លួនថ្ងៃទី៣០-៨-២០១១ នៅពន្ធនាគារខេត្តកំពង់ចាម ។

ត្រូវចោទពីបទ:**រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិស្វាយកាំបិត ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧-៨-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារជនជាប់ចោទលោក[redacted] **អ៊ាវ**

-ដើមបណ្តឹងនិងជាជនរងគ្រោះឈ្មោះ [redacted]**ស្រីនាង** អាយុ១៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិស្វាយកាំបិត ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម ។ស

១៣៦

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤-០៣-២០១២ របស់ឈ្មោះ [redacted] ធារ៉ា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ០៤(ខ) ចុះថ្ងៃទី២២-០២-២០១២ របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

**ឯរឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី២៧-៨-២០១១ វេលាម៉ោង១៩,០០នាទី ឈ្មោះ [redacted] ធារ៉ា ហៅ ឃ្លោក បានស្រវឹងស្រា ហើយបានទៅបត់ជើងធំនៅក្រោយផ្ទះ លុះពេលដើរត្រឡប់មកវិញក៏បានឃើញឈ្មោះ [redacted] ស្រីនាង កំពុងដេកជាមួយម្តាយក្មេករបស់ខ្លួននៅក្រោមផ្ទះ ពេលនោះឈ្មោះ [redacted] ធារ៉ា ក៏ចូលទៅលើកបីឈ្មោះ [redacted] ស្រីនាង យកទៅចំការដំឡូងក្រោយផ្ទះ នៅពេលនោះឈ្មោះ [redacted] ស្រីនាង បានដឹងខ្លួនហើយក៏បានស្រែកថា ម៉ែអើយជួយខ្ញុំផង ឈ្មោះ [redacted] ធារ៉ា ក៏បានដាល់ពោះជនរងគ្រោះចំនួន០២ដៃ និង ច្របាច់ករហូតដល់សន្លប់ ហើយឈ្មោះ [redacted] ធារ៉ា បានបីជនរងគ្រោះទៅដាក់ចំការដំឡូងធ្វើការរំលោភ តែរំលោភមិនបានសំរេច ព្រោះជនល្មើសស្រវឹងស្រាប្រដាប់ភេទមិនឡើងរឹង ឈ្មោះ [redacted] ធារ៉ា ក៏បានខាំបបូរមាត់ ខាំដោះ និងខាំក បណ្តាលឱ្យជនរងគ្រោះមានរបួសស្នាម លុះស្អែកឡើងថ្ងៃទី២៨-៨-២០១១ ជនរងគ្រោះក៏បានប្តឹងសមត្ថកិច្ច ហើយសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនល្មើសកសាងសំណុំរឿង បញ្ជូនមកតុលាការធ្វើការឃុំខ្លួនតែម្តង ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៤(ខ) ចុះថ្ងៃទី២២-០២-២០១២ របស់សាលាដំបូងខេត្តកំពង់ចាម មានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ធារ៉ា ហៅ ឃ្លោក ពីបទ រំលោភសេពសន្ថវៈ មកជាបទប៉ុនប៉ងរំលោភសេពសន្ថវៈ វិញ ។

២-ផ្តន្ទាទោសលើឈ្មោះ [redacted] ធារ៉ា ហៅ ឃ្លោក ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារកំណត់០៨(ប្រាំបី)ឆ្នាំគិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី២៨-៨-២០១១ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្វាយកាំបិត ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧-៨-២០១១ តាមមាត្រា ២៧ និង មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

៣-វត្ថុតាងមាន៖សំពត់ចំនួន០១, ខោចំនួន០១ និង អាវចំនួន០១ ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ ។

៤-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៥-០២-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២-០២-២០១២ ចំពោះមុខជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍រឿងចុះថ្ងៃទី១០-០៧-២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

-បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី៣១-០៧-២០១២ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ៕/

១៣៥

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា: ខ្លួនមិនសុខចិត្តប្ដឹងឧទ្ធរណ៍ ដោយសារសាលាដំបូងខេត្តកំពង់ចាម ចេញសាលក្រមផ្ដន្ទាទោសខ្លួនធ្ងន់ធ្ងរពេក ។ ខ្លួនបានប្រព្រឹត្តមែនតែនាងនិងខ្លួនបានព្រមព្រៀងគ្នាទេ ផ្ទះនាងនិងផ្ទះខ្លួននៅជិតគ្នា ខ្លួនមិនដឹងនាងអាយុប៉ុន្មានទេ នាងមានប្ដីហើយ ប៉ុន្តែមិនបានការទេ ។ ពេលកើតហេតុម៉ោងប្រហែល៧យប់ ខ្លួនផឹកស្រាស្រវឹងខ្លួនឃើញនាងដេកក៏ចាប់បីនាងហើយ នាងមិនរើបំរះទេ គឺនាងព្រមហើយសួរខ្លួនថាបីនាងដល់ណា ។ ខ្លួនមិនបានចាប់បង្ខំនាងទេ ពេលចាប់ដល់ចំការដំឡូងខ្លួនបានចាប់អោបថើបហើយជ្រុលធ្មេញប៉ះដោះនាង បន្ទាប់មកខ្លួនបញ្ឈប់សកម្មភាពដោយប្រដាប់ភេទខ្លួនមិនឡើង ព្រោះខ្លួនស្រវឹងពេក ។ ខ្លួនផឹកស្រាជាមួយឪពុកក្មេកជនរងគ្រោះ ។ ខ្លួនមានប្រពន្ធហើយប្រពន្ធខ្លួននៅផ្ទះ ។ ខ្លួនមិនបានវាយធ្វើបាបនាងទេតែដោយខ្លួនស្រវឹងពេក ទើបបណ្ដាលឱ្យមានស្នាកស្នាមដល់នាង ។ ជនរងគ្រោះមិនខ្លាចខ្លាំខ្លួនទេ ។ ខ្លួនសំណូមពរសុំឱ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសដល់ខ្លួន ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: ជនជាប់ចោទបានសារភាពនូវអំពើរបស់ខ្លួនហើយ ក្នុងរឿងហេតុមានរូបភាពជនរងគ្រោះមានស្នាកស្នាម និង សម្ភារៈគួរឱ្យកត់សំគាល់ ។ ជនជាប់ចោទមិនត្រឹមតែប៉ុនប៉ងធម្មតាទេ តែប៉ុនប៉ងយ៉ាងសាហាវឃោរឃៅទៀតផង បែបយកដំបង ឬ របស់រឹងទៅវាយលើជនរងគ្រោះលើមាត់ ក និងដោះ ដូច្នេះជនជាប់ចោទត្រូវតែទទួលទោសទៅតាមអំពើដែលគេបានប្រព្រឹត្ត ។ ទោះបីជនរងគ្រោះបានដាក់ពាក្យដកពាក្យបណ្ដឹងក៏ដោយ ក៏មហាអយ្យការនៅតែរក្សាបទចោទដដែល ។

-មេធាវីការពារជនជាប់ចោទសន្និដ្ឋានថា: កូនក្ដីខ្លួនបានឆ្លើយសារភាពហើយ មិនមានលាក់លៀមអ្វីទេ ។ តាមចម្លើយកូនក្ដីខ្លួនគឺគ្រាន់តែប៉ះនិងមាត់ទេ រូបភាពថតពេលភ្លឺ ក្រោយកើតហេតុពេលយប់ហើយ គឺមិនមែនថតពេលយប់ពេលកើតហេតុទេ ។ ក្រោយកើតហេតុជនរងគ្រោះបានដាក់ពាក្យប្ដឹង ប៉ុន្តែក្រោយប្ដឹង ហើយក៏បានដកពាក្យបណ្ដឹងវិញ ។ ពេលកើតហេតុជនរងគ្រោះដេកជាមួយម្ដាយក្មេក បើមិនព្រមនាងស្រែកតាំងពីដំបូងទៅហើយៗថែមទាំងសួរកូនក្ដីខ្លួនថាបីដល់ណាទៀត ។ រឿងកើតឡើងពីប្ដីបាត់ប្រពន្ធឯម្ដាយក្មេកបាត់កូនប្រសារទើបកើតរឿងឡើង ។ រឿងរ៉ាវកើតជាលើកទី១ កូនក្ដីខ្លួនមិនដែលបានប្រព្រឹត្តបទល្មើសទេ ម្យ៉ាងជនរងគ្រោះបានដកពាក្យបណ្ដឹងវិញហើយ និង សុំឱ្យតុលាការលើកលែងទោស ហេតុនេះខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សា មេត្តាបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនដល់អប្បរមានៃទោស ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារដែលពាក់ពន្ធ័

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាឧទ្ធរណ៍

**យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤-០៣-២០១២ របស់ឈ្មោះ [redacted] ផារ៉ា ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា៣៧៥ និង មាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-កាលពីរាត្រីថ្ងៃទី២៧-៨-២០១១ វេលាម៉ោង១៩,០០នាទី មានអំពើប៉ុនប៉ងរំលោភសេពសន្ថវៈមួយកើតឡើងក្នុងភូមិស្វាយកាំបិត ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម ដោយជនសង្ស័យឈ្មោះ [redacted] ផារ៉ា ក្រោយពីត្រឡប់ពីផឹកស្រាជាមួយឪពុកក្មេករបស់ជនរងគ្រោះមក ជនសង្ស័យក៏បានដើរកាត់ក្រោយផ្ទះជនរងគ្រោះ ក៏បានឃើញជនរងគ្រោះឈ្មោះ [redacted] **ស្រីនាង** កំពុងដេកលក់នៅលើគ្រែក្រោមផ្ទះជាមួយម្តាយក្មេក ជនសង្ស័យក៏បានចូលទៅចាប់បីជនរងគ្រោះយកទៅចំការដំឡូងក្រោយផ្ទះ បំណងរំលោភសេពសន្ថវៈ ។ ពេលនោះជនរងគ្រោះបានស្រែកឱ្យម្តាយក្មេកជួយ ក៏ត្រូវជនសង្ស័យវាយទៅលើពោះចំនួនពីរដៃរួចហើយប្រុងចាប់រំលោភសេពសន្ថវៈ តែពុំអាចរំលោភសេពសន្ថវៈលើជនរងគ្រោះបាន ដោយសារប្រដាប់ភេទរបស់ជនសង្ស័យមិនរឹងព្រោះស្រវឹងស្រាខ្លាំងពេក ទើបជនសង្ស័យបានខាំដោះ ,កញ្ចឹងក និង បបូរមាត់របស់ជនរងគ្រោះបណ្តាលឱ្យមានរបួសស្នាម ។

៣-ជនជាប់ចោទឈ្មោះ [redacted] **ផារ៉ា** បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធីថា ក្រោយពីផឹកស្រាស្រវឹងរួចមក ខ្លួនបានឃើញជនរងគ្រោះឈ្មោះ [redacted] **ស្រីនាង** ដេកនៅលើគ្រែក្រោមផ្ទះ ខ្លួនក៏ចាប់បីជនរងគ្រោះទៅក្នុងចំការដំឡូងក្រោយផ្ទះ បំណងរួមរក្សជាមួយជនរងគ្រោះ តែដោយ [redacted] និង បាន [redacted] រួចហើយក៏ដើបដើរទៅផ្ទះទៅ ។ ហើយតាមចម្លើយបំភ្លឺរបស់ជនរងគ្រោះ បានបញ្ជាក់ដូចគ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទដែរ ។

៤-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ផារ៉ា ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈប្រព្រឹត្តនៅភូមិស្វាយកាំបិត ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧-៨-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

៥-រឿងក្តីនេះសាលាដំបូងខេត្តកំពង់ចាម បានធ្វើការអង្កេតនិងលើកយកភស្តុតាង មកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៦-ជនជាប់ចោទជាមនុស្សស្ថិតនៅក្នុងវ័យក្មេងមានកំរិតវប្បធម៌ទាប ជាមនុស្សល្ងង់ខ្លៅ ខ្វះការពិចារណាលើអំពើរបស់ខ្លួន ហើយជនជាប់ចោទបានឆ្លើយសារភាពនូវកំហុសរបស់ខ្លួន និង មានការសោក.../

ស្តាយចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមកនេះ ដែលគប្បីតុលាការពិចារណាអំពីស្ថានសម្រាល ទោស តាមមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌ ឱ្យផលដល់ជនជាប់ចោទ ។

៧-សាលក្រមព្រហ្មទណ្ឌលេខ០៤(ច) ចុះថ្ងៃទី២២-០២-២០១២ របស់សាលាដំបូងខេត្តកំពង់ចាម ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ដោយគ្រាន់តែ កែប្រែរយៈពេលនៃការផ្តន្ទាទោសលើជនជាប់ចោទ តាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-៣-២០១២ របស់ឈ្មោះ [redacted] ធារ៉ា ទុកជាត្រឹមត្រូវ តាម ទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៤(ច) ចុះថ្ងៃទី២២-០២-២០១២ របស់សាលាដំបូងខេត្ត កំពង់ចាម ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលនៃការផ្តន្ទាទោសជនជាប់ចោទ ក្នុងចំណុច ទី២ នៃសេចក្តីសម្រេចពីររយៈពេល០៨(ប្រាំបី)ឆ្នាំ មកជារយៈពេល០៥(ប្រាំ)ឆ្នាំ វិញ ។ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខ ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។/.

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។/.

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី.....19.....ខែ.....[illegible].....ឆ្នាំ២០14.
ក្រឡាបញ្ជី

[redacted]